**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះវិហារ**

សំណុំរឿងព្រហ្មទណ្ឌលេខ ២៩៦
ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខ ៣៣
ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២
សាលក្រមព្រហ្មទណ្ឌ
លេខ **១៧** (**ខ**)
ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តព្រះវិហារ**

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ វេលាម៉ោងប្រាំបួនព្រឹក ដោយមានសមាសភាព៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៩៦ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

ឈ្មោះ [redacted] គៀក ភេទស្រី អាយុ៥០ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ធំ មានទីលំនៅបច្ចុប្បន្ននៅភូមិតា [redacted] ខេត្តព្រះវិហារ ឪពុកឈ្មោះ [redacted] ជៀន (ស្លាប់) ម្តាយឈ្មោះ [redacted] គៀន (រស់) ប្តីឈ្មោះ [redacted] ស្ងួន មានកូនចំនួន ០៥នាក់ ប្រវត្តិនៃការផ្តន្ទាទោសពីមុនដោយតុលាការ "គ្មាន" ជានីតិជន។ (ក្រៅឃុំ)

ត្រូវជាប់ចោទពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ ប្រព្រឹត្តនៅភូមិតាកឹង ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦២ ចំណុចទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

ដោយមាន [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។



Scanned with CamScanner

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ១៥៦៨ ដ.ស.ព ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាដំណោះស្រាយលេខ ៣៥៦៨ ព្រ.ទ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៦៥/២០២២ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ

-បានឃើញដីកាសម្រេចដាក់រឿងទៅជំនុំជម្រះលេខ ៨៤/២០២២ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តព្រះវិហារ

## **ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:**

កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ មានករណីកាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃដើម្បីយកធ្វើជាកម្មសិទ្ធិនៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេពស្ថិតនៅភូមិតាកឹង ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ បង្កឡើងដោយជនល្មើសឈ្មោះ [redacted] ភឿក ភេទស្រី អាយុ៥០ឆ្នាំ បានចូលទៅកាប់ព្រៃបានចំនួន ៧.៣២ហិចតា និងសាងសង់ខ្ទម ដើម្បីយកដីមកធ្វើជាកម្មសិទ្ធិរបស់ខ្លួនដោយគ្មានលិខិតអនុញ្ញាត ។

## **នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ភឿក បានឆ្លើយនាពេលសវនាការថា ខ្លួនពិតជាបានទៅកាប់រុករាន ដុតឆ្ការដីព្រៃនោះពិតមែន ប៉ុន្តែខ្លួនពុំបានឈូសឆាយដីព្រៃនោះឡើយ ហើយខ្លួនក៏ពុំបានទៅកាប់ដើមឈើធំៗ ឡើយ គឺដីនោះមានតែដើមឈើតូចៗ ប៉ុណ្ណោះ ដោយប្រើពូថៅ កាំបិត ដែលមានដីទំហំសរុប ៧ហិចតា ជាមួយប្តីរបស់ខ្លួនឈ្មោះ [redacted] សួន និងកូនតូចៗ តាំងពីឆ្នាំ២០១២ មក។ កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ក្រុមការងារបានចុះហាមឃាត់ លុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ បានចុះទៅចាប់ដីរបស់ខ្លួន។ ខ្លួនបានសុំខាងមន្ត្រីដើម្បីរស់នៅ ព្រោះខ្លួនពុំមានដីរស់នៅឡើយ។ បច្ចុប្បន្នខ្លួនសុំដីរបស់គេរស់នៅ។ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ខ្លួន និងប្តីកំពុងនៅផ្ទះ។ ខ្លួនក៏ដឹងថា ដីនេះជាកម្មសិទ្ធិរបស់រដ្ឋដែរ។ មកដល់ពេលបច្ចុប្បន្ននេះ ខ្លួនពុំបានកាប់ឆ្ការព្រៃយកដីនេះបន្តទៀតឡើយ។ ដីនេះ ខ្លួនបានដាំណាំផ្សេងៗ និងស្រូវ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ខ្លួនធ្លាប់ធ្វើកិច្ចសន្យាជាមួយនឹងមន្ត្រីខាងបរិស្ថានមែន។ ខ្លួនសុខចិត្តប្រគល់ដីនេះឲ្យរដ្ឋវិញ ប្រសិនបើរដ្ឋត្រូវការ ប៉ុន្តែពេលនេះ ខ្លួនស្នើសុំបង្កបង្កើនផលសិន ដើម្បីជីវភាពគ្រួសារ ព្រោះខ្លួនមានជីវភាពខ្វះខាតណាស់។

-លោក [redacted] គីរ័ត្ន ជាអនុប្រធានការិយាល័យដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព បានឆ្លើយបំភ្លឺនាពេលសវនាការថា កាលពីថ្ងៃ០៨ ខែមេសា ឆ្នាំ២០២១ កម្លាំងមន្ត្រីឧទ្យានុរក្សចំនួន ០៦ នាក់ បានចុះល្បាតនៅចំណុចភ្នំរាំង ភូមិតាកឹង ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ បានជួបប្រទះជនសង្ស័យចំនួន ០២នាក់ ប្តីប្រពន្ធកំពុងតែប្រព្រឹត្តបទល្មើសកាប់រុករានដីព្រៃ និងសាងសង់ខ្ទម ហើយ



Scanned with CamScanner

មន្ត្រីឧទ្យានក៏បានធ្វើការអប់រំណែនាំឲ្យបញ្ឈប់ការកាប់រុករាន និងឲ្យរុះរើខ្ទមចេញ ហើយបានឲ្យពួកគាត់ធ្វើកិច្ចសន្យា នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ ប៉ុន្តែពួកគាត់មិនព្រមបញ្ឈប់ និងបានឲ្យពួកគាត់ធ្វើកិច្ចសន្យាលើកទី២ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ នៅចំពោះមុខអាជ្ញាធរ ភូមិឃុំ ចូលរួមដឹងឮជាថ្មីម្តងទៀត។ បន្ទាប់មកខាងកម្លាំងបានចុះទៅចំណុចខាងលើម្តងទៀត នៅតែឃើញជនល្មើសទាំងពីរមិនទាន់រុះរើខ្ទមចេញទេ និងបានកាប់រុករានដីព្រៃបន្ត មន្ត្រីឧទ្យានក៏បានដកហូតដីមានទំហំ ៧,៣២ ហិចតា មកដែនគ្រប់គ្រងវិញ និងបញ្ឈប់ការកាប់រុករានដីព្រៃហើយមិនព្រមឲ្យមានការដាំដំណាំផ្សេងៗ ប៉ុន្តែអ្នកទាំងពីរមិនព្រមស្តាប់ការណែនាំ និងគោរពតាមកិច្ចសន្យារបស់ដែនជម្រកទេ ហើយថែមទាំងផ្តើននិងសមត្ថកិច្ច មិនព្រមរុះរើខ្ទមចេញ ហើយនៅតែបន្តកាប់រុករានដីព្រៃថែមទៀត និងគ្រប់គ្រងលើដីនេះដដែល។ ចំពោះដីដែលជនជាប់ចោទធ្វើសកម្មភាពនេះ ពិតជាស្ថិតនៅក្នុងដែនការពាររបស់ដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ភូមិសាស្ត្រខេត្តព្រះវិហារ ប្រាកដមែន។ ដីនេះ មិនមែនជាដីបុស្សចាស់ឡើយ។ នៅលើទីតាំងដីនេះ គឺមានគ្រួសារគាត់តែប៉ុណ្ណោះដែលបានកាប់ឆ្ការ។ នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ គឺពុំមានដំណាំអ្វីឡើយ ប៉ុន្តែនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ស្រាប់តែឃើញមានដំណាំចេក ស្វាយ ដើមស្វាយចន្ទី។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ស្នើសុំរក្សាបទចោទប្រកាន់នៅដដែល ហេតុដូច្នេះស្នើសុំឲ្យតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានការពារថា ដោយសារកូនក្តីរបស់ខ្លួនបានសារភាពនូវទោសកំហុស ហេតុដូច្នេះ ស្នើសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសឲ្យដល់កូនក្តីខ្លួន ដោយហេតុថា កូនក្តីខ្លួនមានជីវភាពខ្វះខាត សកម្មភាពបទល្មើសប្រព្រឹត្តឡើងដោយសារកត្តាជីវភាព កូនក្តីខ្លួនមានអាយុច្រើនហើយ ស្នើសុំតុលាការមេត្តាបន្ធូរបន្ថយទោស។

-សម្តីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] គៀក បានស្នើសុំឲ្យតុលាការមេត្តាបញ្ចប់រឿង និងស្នើសុំឲ្យតុលាការមេត្តាបន្ធូរបន្ថយទោស។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនាពេលសវនការ

ក្រោយពីបានស្តាប់ចម្លើយបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌នាពេលសវនាការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទនាពេលសវនាការ

ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានាដែលមានក្នុងសំណុំរឿង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សាលាដំបូងខេត្តព្រះវិហារ យល់ឃើញថា

១.តុលាការជំនុំជម្រះទទួលបានបណ្តឹងតាមដីកាដំណោះស្រាយលេខ ៣៤៦៨ ព្រ/ទ ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះវិហារ ដែលបានបញ្ជូនជនជាប់ចោទ ឈ្មោះ [redacted] ភឿក ភេទស្រី អាយុ៥០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) មកតុលាការដើម្បីជំនុំជម្រះ ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅភូមិតាកឹង ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៦២ ចំណុចទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ**។

២.ក្រោយពីបានបញ្ចប់ការសួរដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទបានសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួនថា ខ្លួនពិតបានកាប់គាស់រុករានព្រៃយកដីធ្វើជាកម្មសិទ្ធិ លើទំហំប្រមាណជា ០៧ហិកតាជាង ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃគូលែនព្រហ្មទេព ភូមិតាកឹង ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ ប្រាកដមែន ចម្លើយសារភាពរបស់ជនជាប់ចោទស្របតាមចម្លើយបំភ្លឺរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងការពិនិត្យភស្តុតាងនានាក្នុងសំណុំរឿង ដែលអាចឲ្យតុលាការជឿជាក់បានថា ជនជាប់ចោទបានប្រព្រឹត្តដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន ហេតុដូច្នេះតុលាការមានមូលដ្ឋានគ្រប់គ្រាន់សម្រេចតាមច្បាប់បាន តាមបញ្ញត្តិមាត្រា **៦២ ចំណុច១** នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងតាមបញ្ញត្តិមាត្រា **៣៥០ កថាខណ្ឌ២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.តំណាងអយ្យការ បានស្នើសុំរក្សាបទចោទប្រកាន់ទុកជាការ និងស្នើសុំឲ្យតុលាការធ្វើការពិចារណា និងសម្រេចតាមច្បាប់ គប្បីតុលាការពិចារណា។

៤.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យមានការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម ដែលត្រូវបានច្បាប់ការពារតាមបញ្ញត្តិមាត្រា **៦២ ចំណុទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ**។

៥.ជនជាប់ចោទជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងខុសត្រូវពីផលវិបាកដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន និងមិនមានភស្តុតាងណាមួយ បញ្ជាក់ពីការមានវិបល្លាសស្មារតីរបស់ជនជាប់ចោទ ដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះមុខច្បាប់។

៦.មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភឿក ភេទស្រី អាយុ៥០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ពីបទ **កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ** ប្រព្រឹត្តនៅភូមិតាកឹង ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៦២ ចំណុចទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ**។



Scanned with CamScanner

៧.ជនជាប់ចោទបានសារភាពនូវកំហុសរបស់ខ្លួន ជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង គប្បីគុលាការពិចារណាអំពីលក្ខខណ្ឌដែលនាំឲ្យមានការព្យួរទោសបាន តាមបញ្ញត្តិមាត្រា ១០៧ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសាលាដំបូងខេត្តព្រះវិហារ**

**វិនិច្ឆ័យសេចក្តី**

ផ្តន្ទាទោស ឈ្មោះ [redacted] ភៀក ភេទស្រី អាយុ៥០ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥ (ប្រាំ) ឆ្នាំ តែទោសនេះអនុវត្តព្យួរ ពីបទ កាប់គាស់ រុករានដីព្រៃ ឆ្ការដុត និងឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ បទល្មើសប្រព្រឹត្តនៅភូមិតាកឹង ឃុំថ្មី ស្រុកគូលែន ខេត្តព្រះវិហារ តាមបញ្ញត្តិមាត្រា ៦២ ចំណុចទី១ នៃច្បាប់ស្តីពីតំបន់ការពារធម្មជាតិ កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២១។

សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ភៀក។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ព្រះវិហារ, ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២

| **ក្រឡាបញ្ជីសវនាការ** | **ក្រុមប្រឹក្សាជំនុំជម្រះ** | **ក្រុមប្រឹក្សាជំនុំជម្រះ** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ព្រះវិហារ, ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner